ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
Nº ០៧៧.៧៧./រប.សជណ
/១៦

# សេចក្តីជូនដំណឹង
## ស្តីពីការហាមឃាត់ការប្រើប្រាស់យន្តហោះខ្នាតតូច (Drone) ក្នុងតំបន់រមណីយដ្ឋានអង្គរ និងបរិវេណប្រាសាទ

អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបររថយន្តដឹកជញ្ជូនភ្ញៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបថា ដើម្បីធានាសុវត្ថិភាពជូនប្រជាពលរដ្ឋ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងបង្ការផលប៉ះពាល់ជាយថាហេតុដល់ប្រាសាទបុរាណ ក៏ដូចជារក្សាសន្តិសុខសណ្តាប់ធ្នាប់នៅតាមប្រាសាទ អាជ្ញាធរអប្សរាសូមហាមឃាត់ការប្រើប្រាស់យន្តហោះខ្នាតតូច Drone គ្រប់ប្រភេទ ដើម្បីផ្តិតយករូបភាពក្នុងតំបន់រមណីយដ្ឋានអង្គរ និងប្រាសាទ លើកលែងតែក្នុងករណីចាំបាច់ដែលទទួលបានការអនុញ្ញាតពីអាជ្ញាធរអប្សរា។ ក្នុងករណីមិនគោរពតាមការណែនាំ អាជ្ញាធរអប្សរាសហការជាមួយនគរបាលការពារបេតិកភណ្ឌ នឹងបញ្ឈប់រាល់សកម្មភាពបង្ហោះណាដែលគ្មានការអនុញ្ញាតពីអាជ្ញាធរអប្សរា ឬឈានដល់ការដកហូតសម្ភារៈនានាដែលបម្រើដល់ការបង្ហោះ និងរក្សាទុកដើម្បីដោះស្រាយតាមនីតិវិធី។

អាជ្ញាធរអប្សរាសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ នឹងចូលរួមគោរពអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងផ្សព្វផ្សាយបន្តឱ្យបានទូលំទូលាយ។ ឯ/

សៀមរាប ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៦

អគ្គនាយក

ស៊ុំ ម៉ាប់

<u>ចម្លងជូន៖</u>
- សាលាខេត្តសៀមរាប
- គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជុំវិញខេត្ត
- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
- អង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប
- គ្រឹះស្ថានអង្គរ
- សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមសណ្ឋាគារ
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមអ្នកបើកបររថយន្តដឹកជញ្ជូនភ្ញៀវទេសចរ
- គ្រប់នាយកដ្ឋាន និងអង្គភាពចំណុះ
- ឯកសារ-កាលប្បវត្តិ




P. PENH :
Russian Blvd, Sangkat Mealapneap, Khan 7Makara
855-23) 215 771
855-23) 216 776

SIEM REAP :
Phum Bang Korng, Sangkat Amoil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576


CS Scanned with CamScanner